ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ ;....០៣៤ ប្រ.ក.....ប.ស្ថ

# ប្រកាស
## ស្ដីពី
## ការទទួលស្គាល់ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ -គីរីសុខសាន្ត- នៃដែនជម្រកសត្វព្រៃ -ព្រៃឡង់- ស្ថិតក្នុងភូមិគីរីសុខសាន្ត ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

៣*៤

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម០១២/០៦១៨/ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៧៤អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតដែនជម្រកសត្វព្រៃ «ព្រៃឡង់»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.** ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ **«គីរីសុខសាន្ត»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតក្នុងភូមិគីរីសុខសាន្ត ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

**ប្រការ២.** សហគមន៍តំបន់ការពារធម្មជាតិ **«គីរីសុខសាន្ត»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» មានផ្ទៃដីទំហំ **១៣៣៨,៥៤ ហិកតា** ដូចមានផែនទីជាឧបសម្ព័ន្ធកំណត់ដោយបណ្ដាចំណុចគោលដែលមាននិយាមកាដូចក្នុងតារាងខាងក្រោម៖



អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 576653 | 1518504 | 9 | 571541 | 1517810 |
| 2 | 575422 | 1518444 | 10 | 571287 | 1517900 |
| 3 | 574242 | 1518385 | 11 | 570618 | 1517097 |
| 4 | 573005 | 1519168 | 12 | 572094 | 1516402 |
| 5 | 571763 | 1519953 | 13 | 573692 | 1515650 |
| 6 | 571361 | 1519339 | 14 | 575710 | 1516546 |
| 7 | 571361 | 1518969 | 15 | 576135 | 1516944 |
| 8 | 571996 | 1518408 | | | |

**ប្រការ៣.** ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«គីរីសុខសាន្ត»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤.** សហគមន៍តំបន់ការពារធម្មជាតិ **«គីរីសុខសាន្ត»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ សហគមន៍តំបន់ការពារធម្មជាតិ **«គីរីសុខសាន្ត»** ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន។

**ប្រការ៥.** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកគ្រប់អគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង នាយកតំបន់ដែនជម្រកសត្វព្រៃ «ព្រៃឡង់» និងសហគមន៍តំបន់ការពារធម្មជាតិ **«គីរីសុខសាន្ត»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ៍ ៣ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តស្ទឹងត្រែង
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច

# ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិគីរីសុខសាន្ត ក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់
## ភូមិសាស្ត្រភូមិគីរីសុខសាន្ត ឃុំអន្លង់ភេ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ផ្ទៃដី១៣៣៨,៥៤ហិកតា

ឧបសម្ព័ន្ធ : ប្រកាសលេខ ០៣៦ ចុះថ្ងៃទី០៨ ខែ មករា ឆ្នាំ២០១៩ របស់ក្រសួងបរិស្ថាន




| Id | Labal | Coor_X | Coor_Y |
|---|---|---|---|
| 1 | A | 576653 | 1518504 |
| 2 | B | 575422 | 1518444 |
| 3 | C | 574242 | 1518385 |
| 4 | D | 573005 | 1519168 |
| 5 | E | 571763 | 1519953 |
| 6 | F | 571361 | 1519339 |
| 7 | G | 571361 | 1518969 |
| 8 | H | 571996 | 1518408 |
| 9 | I | 571541 | 1517810 |
| 10 | J | 571287 | 1517900 |
| 11 | K | 570618 | 1517097 |
| 12 | L | 572094 | 1516402 |
| 13 | M | 573692 | 1515650 |
| 14 | N | 575710 | 1516546 |
| 15 | O | 576135 | 1516944 |